# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ១៧ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទាន**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥អនក្រ. ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបែងចែកឥណ ទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** : ត្រូវបានផ្ទេរឥណទាន ពីជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន៣.៧២៤លានរៀល (បីពាន់ប្រាំពីររយម្ភៃបួនលានរៀលគត់) មកជំពូក៣២ (អន្តរាគមន៍ ក្នុងវិស័យអន្តរជាតិ) ក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ។

**មាត្រា ២** : ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីចាត់វិធានការផ្នែក ហិរញ្ញវត្ថុ អោយបានទាន់ពេលវេលាសំរាប់ប្រទេសកម្ពុជា ដែលត្រូវជាសមាជិក អាស៊ាន ក្នុងឆ្នាំ ១៩៩៧ ខាងមុខនេះ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថ - លេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ : ១៨ អនក្រ.បក

## ស្តីពី

## អាហារូបករណ៍ និង របបឧបត្ថម្ភជីវភាពអន្តេវាសិក

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា